ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

លេខ: 59 PR-18/EoJ ថ្ងៃទី២៨ខែធ្នូ ឆ្នាំ២០១៨

## ជំនួយរបស់ជប៉ុនសំរាប់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)

កាលពីថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០១៨ រដ្ឋាភិបាលជប៉ុនបានបញ្ចេញប្រាក់ចំនួន**១,២លានដុល្លាអាមេរិក** ជាវិភាគទានសំរាប់ឆ្នាំសារពើពន្ធ ២០១៨ របស់ខ្លួន ដើម្បីផ្តល់ជូនភាគីអង្គការសហប្រជាជាតិនៃថវិកាអង្គជំនុំជម្រះ វិសាមញ្ញក្នុងតុលាការកម្ពុជា ។

រដ្ឋាភិបាលជប៉ុនបានសំរេចចិត្តផ្តល់វិភាគទាននេះ ដើម្បីបន្តទ្រទ្រង់ដំណើរការរបស់សាលាក្តីខ្មែរក្រហម ។ ប្រទេសជប៉ុនកត់សំគាល់នូវការវិវឌ្ឍកាលពីពេលថ្មីៗនេះនៃ អ.វ.ត.ក ជាពិសេសសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណុំរឿង ០០២/០២ ហើយទន្ទឹមនឹងនេះលើកទឹកចិត្តឱ្យ អ.វ.ត.ក បន្តដំណើរការលើសំណុំរឿងដែលនៅសេសសល់ក្នុងរបៀបមួយមានភាពត្រឹមត្រូវ មានប្រសិទ្ធភាព និងឆាប់រហ័ស ដោយហេតុថា ជនជាប់ចោទមានវ័យកាន់តែចាស់ជរា និងសុខភាពទន់ខ្សោយ និងដើម្បីសំរេចបាននូវយុត្តិធម៌ ដែលកំពុងត្រូវបានទន្ទឹងរង់ចាំអស់រយៈពេលយ៉ាងយូរមកហើយ សំរាប់ប្រជាជនកម្ពុជា ។

រដ្ឋាភិបាលជប៉ុនផ្តល់សារៈសំខាន់ទៅលើសាលាក្តីខ្មែរក្រហម ដោយផ្អែកលើទស្សនៈចំនួនបី។ ទីមួយ ការកាត់ក្តីខ្មែរក្រហមគឺជាដំណាក់កាលបញ្ចប់នៃដំណើរការស្វែងរកសន្តិភាពនៅកម្ពុជា ដើម្បីបង្ការទប់ស្កាត់ការកើតមានឡើងវិញនៃអំពើឃោរឃៅ ដែលបានប្រព្រឹត្តឡើងនៅក្នុងរបបខ្មែរក្រហម ។ ទីពីរ សាលាក្តីខ្មែរក្រហមនេះនឹងជួយស្វែងរកយុត្តិធម៌ជូនជនរងគ្រោះនៃរបបខ្មែរក្រហម ដែលប្រការនេះនឹងរួមចំណែកដល់ការផ្សះផ្សាជាតិឡើងវិញ ។ ទីបី សាលាក្តីនេះនឹងរួមចំណែកដល់ការពង្រឹងនីតិរដ្ឋនៅកម្ពុជា ។

រដ្ឋាភិបាលជប៉ុនបាន និងកំពុងជួយដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តាំងពីដើមដំបូងរៀងមក ហើយគិតត្រឹមថ្ងៃនេះ ជំនួយហិរញ្ញវត្ថុពីប្រទេសជប៉ុនសំរាប់តុលាការនេះ មានចំនួន ៨៧,៥៩លានដុល្លាអាមេរិកដោយគិតរួមទាំងការបញ្ចេញថវិកាលើកនេះ ដែលប្រហាក់ប្រហែលនឹង ២៩% នៃថវិកាសរុបផ្តល់ដោយប្រទេសផ្តល់ជំនួយ ជូនភាគីជាតិ និងភាគីអង្គការសហប្រជាជាតិនៃ អ.វ.ត.ក ។ លើសពីនេះទៅទៀត ប្រទេសជប៉ុនរួមជាមួយប្រទេសបារាំង ក្នុងឋានៈជាសហប្រធាននៃមិត្តរបស់ អ.វ.ត.ក. បានតាមដានដំណើរការរបស់តុលាការនេះយ៉ាងសកម្ម។

ស្ថានទូតជប៉ុន អាស័យដ្ឋានលេខ ១៩៤ មហាវិថីព្រះនរោត្តម ទូរសព្ទ: (០២៣) ២១៧ ១៦១/៤ ទូរសារ: ០២៣-២១៦ ១៦២
វេបសាយផ្លូវការ: www.kh.emb-japan.go.jp